ការជិះរថយន្តក្រុង។

ចូរប្រើវិបសៃរបស់ Metro, បណ្តាញ Metro តាមអ៊ិនធឺណិត www.kingcounty.gov/metro ឬទូរស័ព្ទលេខ (206) 553-3000 ដើម្បីរកផ្លូវសំរាប់ការធ្វើដំណើររបស់អ្នក, រកចំណតរថយន្តក្រុងរបស់អ្នក និងធ្វើគំរោងការធ្វើដំណើររបស់អ្នក។

នៅចំណតរថយន្តក្រុង ចូររកមើលលេខរថយន្តរបស់អ្នកនៅលើប្រកាសចំណតរថយន្តក្រុង។ នៅពេលរថយន្តក្រុងមកដល់ ចូរឆែកលេខរថយន្តនិងទីដៅធ្វើដំណើរ នៅលើកញ្ចក់ខាងមុខ។ ចូលក្នុងរថយន្តក្រុងតាមទ្វារ ខាងមុខ និងបង់ឈ្នួលថ្លៃរថយន្តក្រុង។

កន្លែងអង្គុយនៅខាងមុខគឺទុកបំរុងឲ្យមនុស្សចាស់និងមនុស្សពិការ។ សូមរក្សាផ្លូវដើរក្នុងរថយន្តក្រុងឲ្យនៅទំនេរ ដើម្បីទុកឲ្យអ្នកដទៃដើរទៅកន្លែងអង្គុយរបស់ពួកគេ។

អ្នកអាចបង់ថ្លៃជិះរថយន្ត Metro ដោយប្រាក់សុទ្ធ, ប្រើសំបុត្រប្តូរជិះ Metro, សំបុត្រ Metro, ឬកាត ORCA ។ អ្នកនឹងត្រូវគោះកាត ORCA របស់អ្នកបន្តើរៗត្រង់ប្រអប់, ដាក់ប្រាក់ថ្លៃឈ្នួលឲ្យត្រូវ ពិតប្រាកដ ឬ សំបុត្រក្នុងប្រអប់ថ្លៃឈ្នួលនៅខាងមុខរថយន្តក្រុងឬបង្ហាញសំបុត្រប្តូរជិះរបស់អ្នកទៅអ្នកបើករថយន្ត។ អ្នកបើករថយន្តគ្មានប្រាក់ជាប់ខ្លួនទេ។

នៅពេលរថយន្តក្រុងទៅដល់ជិតចំណតដែលអ្នកត្រូវចុះ ចូរទាញខ្សែនៅខាងលើបង្អួច ដើម្បីឲ្យអ្នកបើក រថយន្តក្រុងដឹងថាអ្នកចង់ចុះ។

ឈ្នួល

Metro មាន “ឈ្នួលតាមតំបន់” ពីរផ្នែក។ បើអ្នកឆ្លងកាត់ព្រំប្រទល់ក្រុង Seattle, អ្នកត្រូវបង់ឈ្នួលពីរតំបន់។ ឈ្នួលគឺច្រើនជាងបន្តិចនៅពេលធ្វើដំណើរក្នុងម៉ោងមមារញឹក គឺថ្ងៃច័ន្ទ-សុក្រ ម៉ោង 6-9 ព្រឹក និងម៉ោង 3 - 6 ល្ងាច។

បង់ឈ្នួលដោយប្រើកាត ORCA

ការធ្វើដំណើរគឺងាយស្រួលសំរាប់ជិះរថយន្តក្រុង និង Sound Transit ហើយនិងរទេះភ្លើង នៅពេលអ្នកប្រើកាត ORCA ដើម្បីបង់ថ្លៃសំបុត្រ។ កាត ORCA អាចជាកាត “E-Purse” ដែលក្នុងនោះអ្នកបង់ប្រាក់ដើម្បីបង់ថ្លៃសំបុត្ររបស់អ្នក។ ឬអ្នកអាចបង់សំរាប់មួយខែម្តង សំរាប់សំបុត្រជិះរថយន្ត ក្រុង ដែលសំបុត្រនោះឲ្យអ្នកជិះរថយន្តដោយគ្មានកំណត់សំរាប់មួយខែ។ អ្នកអាចទិញកាត ORCA នៅការិយាល័យលក់សំបុត្រនៃក្រុមហ៊ុន Metro, នៅម៉ាស៊ីនលក់សំបុត្រនៅចំណតរទេះភ្លើង, តាមអ៊ិនធឺណិត www.orcacard.com, ឬតាមទូរស័ព្ទលេខ 1-888-988-6722 ។ កាត ORCA មិនអាចប្រើបានទេលុះត្រាតែអ្នកដាក់ប្រាក់ បន្ថែម ឬដាក់ប្រាក់សំរាប់ការធ្វើដំណើរមួយខែ។

តំបន់ដែលអនុញ្ញាតជិះបន្ថយឈ្នួល (RRFP)

បើអ្នកមានអាយុ 65 ឆ្នាំឬចាស់ជាង ឬក៏មានពិការភាពអ្នកអាចដាក់ពាក្យសុំទទួលកាត RRFP ORCA ដែលនឹងអនុញ្ញាតឲ្យអ្នកជិះដោយបន្ថយថ្លៃឈ្នួល។ ចូរទាក់ទងទៅការិយាល័យលក់សំបុត្រនៃក្រុមហ៊ុន Metro ដើម្បីពត៌មានច្រើនថែមទៀត។

ប្រដាប់លើកនៃរថយន្តក្រុង

គ្រប់រថយន្ត Metro ទាំងអស់មានផ្លូវជំរាល ឬប្រដាប់លើកឡើងជិះ និងអាចចុះឡើងបានសំរាប់ពលរដ្ឋចាស់ៗ, មនុស្សពិការ, និងអ្នកជិះជាច្រើនទៀតដែលប្រើកៅអីកង់។

ប្រដាប់ព្យួរកង់

គ្រប់រថយន្ត Metro ទាំងអស់មានប្រដាប់ព្យួរកង់ដែល ដាក់បានកង់បី។ ចូរឲ្យអ្នកបើករថយន្តក្រុងដឹង បើអ្នក មានផែនការដាក់កង់របស់អ្នកឡើងឬចុះ។

តារាងម៉ោងពេល

តារាងម៉ោងពេលនៃរថយន្តក្រុងបង្ហាញពីពេលវេលា, ឈ្នួលនិងផែនទី។ គឺអាចមាននៅក្នុងរថយន្តក្រុង, នៅតាមបណ្ណាល័យ និងតាម malls ហើយនិងនៅតាមការិយាល័យបំរើភ្ញៀវនៃក្រុមហ៊ុន Metro ។

ធាតុអាកាសពេលធ្លាក់ទឹកកក

នៅពេលធ្លាក់ទឹកកក ហើយនិងមានទឹកកកលើថ្នល់, ឬនៅពេលរថយន្តក្រុងត្រូវរង្គាក ដោយសារ តែមានការបន្ទាន់អាសន្ន ចូរទូរស័ព្ទតាមលេខ 206-553-3000 សំរាប់ពត៌មាននានាជាភាសារបស់អ្នក។

ការិយាល័យបំរើភ្ញៀវនៃក្រុមហ៊ុនមេត្រ

King Street Center
201 S Jackson St, Seattle
ថ្ងៃច័ន្ទ - សុក្រ, ម៉ោង 8 ព្រឹក – 5 ល្ងាច

ចាត់របស់ & ឃើញរបស់
ថ្ងៃច័ន្ទ - សុក្រ, ម៉ោង 9 ព្រឹក - 1 រសៀលនិងម៉ោង 2 រសៀល - 5 ល្ងាច

Downtown Seattle Transit Tunnel
Westlake Station – 3rd Ave & Pine St

ពត៌មាន
ទូរស័ព្ទ .....206-553-3000 TTY លេខបន្ត: 711
គឺអាចមានសេវាបកប្រែភាសា
បណ្តាញ Metro តាមអ៊ិនធឺណិត. www.kingcounty.gov/metro